# ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន

មេធាវី **គង់ សំអុន** និង Anta GUISSÉ

ភ្នំពេញ/ប៉ារីស

ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Sept-2018, 10:00
CMS/CFO: Sann Rada

**ជូនចំពោះ៖** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ព្រមទាំងភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០២

**កម្មវត្ថុ៖** សំណើសុំព័ត៌មានផ្លូវការអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម

---

លោកប្រធានជាទីគោរព

នៅពេលបិទសវនាការលើអង្គសេចក្ដីនៃសំណុំរឿង ០០២/០២ លោកប្រធានបានប្រកាសថា “អង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការប្រកាសសាលក្រម ដល់ភាគី និងសាធារណជនជ្រាបបានមុន ក្នុងពេលសមស្រប”[1]។

ក្នុងសំណុំរឿង ០០២/០១ លោកប្រធានបានជូនដំណឹងអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម ដល់ភាគីនានាជាងពីរខែមុន[2]។ ទោះជាយ៉ាងនេះក្ដី យើងខ្ញុំយល់ច្បាស់ថា វិធាន ៩៨(១) នៃវិធានផ្ទៃក្នុង មិនបានកំណត់ពេលវេលាសម្រាប់ការជូនដំណឹងទេ[3] ហើយយើងខ្ញុំមិនដឹងថា ក្នុងសំណុំរឿង ០០២/០២ តើលោកប្រធាននឹងអនុវត្តដូចសំណុំរឿង ០០២/០១ ដែរឬទេ។

---

[1] ប្រតិចារឹកសវនាការ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ **E1/528.1** ក្រោយម៉ោង ១១ និង ១០ នាទីព្រឹក។

[2] ដីកា ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E310** ដែលកំណត់កាលបរិច្ឆេទប្រកាសសាលក្រម ក្នុងសំណុំរឿង ០០២/០១ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤។

[3] វិធាន៩៨ (១) នៃវិធានផ្ទៃក្នុង៖ “ពេលដែលសាលក្រមមិនត្រូវបានប្រកាសក្នុងពេលសវនាការចុងក្រោយទេ ប្រធានអង្គជំនុំជម្រះត្រូវជូនដំណឹងដល់ភាគីអំពីការកំណត់កាលបរិច្ឆេទ ដើម្បីប្រកាសសាលក្រម”។

តាមរយៈការព្យាករណ៍នៅក្នុងផែនការបញ្ចប់ការងារចុងក្រោយ យើងខ្ញុំយល់ថា លោកប្រធានគ្រោងនឹងប្រកាសសាលក្រម នៅខែវិច្ឆិកា ឆ្នាំ២០១៨[4] ប៉ុន្តែ យើងខ្ញុំចង់បានព័ត៌មានផ្លូវការឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន សម្រាប់គោលបំណងរដ្ឋបាល។

ម្យ៉ាង ព័ត៌មាននេះចាំបាច់ណាស់ ដើម្បីឲ្យយើងខ្ញុំអាចរៀបចំពេលវេលាទំនេរ និងជាពិសេស ការធ្វើដំណើររបស់មេធាវីអន្តរជាតិមកទីក្រុងភ្នំពេញ ក្នុងពេលសមស្រប។ ការទទួលបានសំបុត្រយន្តហោះតាមរដ្ឋបាលត្រូវការពេលយ៉ាងតិចក៏មួយខែដែរ។

ម្យ៉ាងទៀត ការជូនដំណឹងជាផ្លូវការអំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម មានផលប៉ះពាល់លើការជ្រើសរើសបុគ្គលិក សម្រាប់ដំណាក់កាលបណ្តឹងសាទុក្ខ។ ជាក់ស្តែង អង្គភាពគាំពារការការពារក្តីបានពន្យល់ប្រាប់យើងខ្ញុំថា ការិយាល័យរដ្ឋបាលនឹងអនុញ្ញាតឲ្យយើងខ្ញុំចាប់ផ្តើមដំណើរការជ្រើសរើសបុគ្គលិកតែចាប់ពីពេលប្រកាសផ្លូវការប៉ុណ្ណោះ[5]។ ក៏ប៉ុន្តែ ដូចលោកប្រធានជ្រាបស្រាប់ហើយ ដំណើរការរដ្ឋបាលទាំងនេះត្រូវការពេលច្រើនណាស់។ លើសពីនេះទៀត អនាគតសមាជិកថ្មីនៃក្រុមមេធាវីការពារក្តីចាំបាច់ត្រូវយល់ច្បាស់អំពីសំណុំរឿង មុនពេលប្រកាសសាលក្រម ដើម្បីអាចធ្វើការលើបណ្តឹងសាទុក្ខបាន។ ដូច្នេះ យើងខ្ញុំចង់មានលទ្ធភាពអាចចាប់ផ្តើមដំណើរការរដ្ឋបាលទាំងនេះ ឲ្យបានឆាប់បំផុត។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាផ្តល់ព័ត៌មានផ្លូវការអំពីកាលបរិច្ឆេទប្រកាសសាលក្រម ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ទោះជាកាលបរិច្ឆេទច្បាស់លាស់ក្តី ឬប្រហាក់ប្រហែលក្តី)។

យើងខ្ញុំទន្ទឹងរង់ចាំចម្លើយពីលោកប្រធាន និងសូមអរគុណទុកជាមុនសម្រាប់ការផ្តល់ព័ត៌មានទាំងនេះ។

សូមលោកប្រធានមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**គង់ សំអុន** Anta GUISSÉ

---

[4] ផែនការបញ្ចប់ការងារ កំណែប្រែលើកទី ១៧ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៥។

[5] អនុស្សរណៈរបស់លោក Isaac ENDELEY ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ មានចំណងជើងថា៖ *"សំណើសុំបង្កើនថវិកាសម្រាប់បណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២"*។